ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍
និងព័ត៌មាន

---------

# សេចក្តីជូនព័ត៌មាន
# ស្តីពីលទ្ធផលកិច្ចប្រជុំកំពូលអាស៊ានលើកទី ៣០
# ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៧ ម៉ានីល សាធារណរដ្ឋហ្វីលីពីន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៣០ ក្រោមមូលបទ «រួមគ្នាជាដៃគូដើម្បីធ្វើការផ្លាស់ប្តូរ រួមចំណែកជាមួយពិភពលោក» ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១៧ នៅទីក្រុងម៉ានីល សាធារណរដ្ឋហ្វីលីពីន តបតាមការអញ្ជើញរបស់ឯកឧត្តម រ៉ូឌ្រីហ្គោ រ៉ូ ឌូតឺតេ ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន។ ក្នុងក្របខ័ណ្ឌកិច្ចប្រជុំកំពូលអាស៊ានលើកទី៣០នេះ សម្តេចតេជោ ក៏បានចូលរួមក្នុងជំនួបរវាងថ្នាក់ដឹកនាំអាស៊ានជាមួយតំណាងអន្តរសភាអាស៊ាន និងជំនួបរវាងថ្នាក់ដឹកនាំអាស៊ានជាមួយតំណាងយុវជនអាស៊ាន។ សម្តេចតេជោក៏មានជំនួបទ្វេភាគីជាមួយនឹងឯកឧត្តម រ៉ូឌ្រីហ្គោ រ៉ូ ឌូតឺតេ ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីនផងដែរ។

ក្នុងអំឡុងពេលកិច្ចប្រជុំ ថ្នាក់ដឹកនាំមានការពិភាក្សាស៊ីជម្រៅ និងផ្លាស់ប្តូរយោបល់ប្រកបដោយលទ្ធផលលើបញ្ហាសំខាន់ៗជាច្រើនដែលជាផលប្រយោជន៍ និងចំណាប់អារម្មណ៍រួមរបស់អាស៊ាន ស្តីពីសសរគ្រឹះទាំងបីរបស់សហគមន៍អាស៊ាន ខួបលើកទី៥០របស់អាស៊ាន និងចំណុចអទិភាពទាំង៦សម្រាប់ឆ្នាំ២០១៧ ដែលមានដូចជា:

១) ការយកចិត្តទុកដាក់លើប្រជាជន និងយកប្រជាជនជាស្នូល
២) សន្តិភាព និងស្ថិរភាពនៅក្នុងតំបន់
៣) កិច្ចសហប្រតិបត្តិសន្តិសុខ និងក្នុងលំហសមុទ្រ
៤) ការរីកចម្រើនរួមប្រកបដោយគំនិតច្នៃប្រឌិត
៥) ភាពរឹងមាំរបស់អាស៊ាន និង
៦) អាស៊ានៈ គំរូនៃសមាហរណកម្មតំបន់ អ្នកដើរតួលើឆាកសាកលលោក

ថ្នាក់ដឹកនាំអាស៊ានបានលើកសរសើរការងាររបស់ផ្នែកជំនាញនានារបស់អាស៊ាន ចំពោះការអនុវត្តប្រកបដោយប្រសិទ្ធភាព និងពេញលេញឯកសារគ្រឹះឆ្នាំ២០២៥ របស់សហគមន៍សង្គមនយោបាយ-

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

សន្តិសុខអាស៊ាន សហគមន៍សេដ្ឋកិច្ចអាស៊ាន និងសហគមន៍សង្គម-វប្បធម៌អាស៊ាន។ ថ្នាក់ដឹកនាំ ក៏បានកត់សំគាល់កិច្ចប្រឹងប្រែងការងារបឋមរបស់គណៈកម្មាធិការសម្របសម្រួលការតភ្ជាប់អាស៊ាន និងក្រុមការងារគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន ដែលរួមមានផែនទីបង្ហាញផ្លូវ និងគោលការណ៍ណែនាំនានា សម្រាប់ការអនុវត្តផែនការមេនៃការតភ្ជាប់អាស៊ានឆ្នាំ២០២៥ និងផែនការការងារស្តីពីគំនិតផ្តួចផ្តើមអាស៊ានដំណាក់កាលទី៣ (២០១៦-២០២០)។

ថ្នាក់ដឹកនាំបានគូសបញ្ជាក់ពីសារសំខាន់ក្នុងការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះមាត្រាពាក់ព័ន្ធនានារបស់ធម្មនុញ្ញអាស៊ាន ក្នុងការធ្វើបច្ចុប្បន្នភាពធម្មនុញ្ញអាស៊ាន និងរំពឹងយកមកពិនិត្យពិចារណា នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១។

លើផ្នែកកិច្ចសហប្រតិបត្តិការនយោបាយនិងសន្តិសុខ ថ្នាក់ដឹកនាំមានសេចក្តីរីករាយចំពោះវឌ្ឍនភាពដែលសម្រេចបានក្នុងការអនុវត្តឯកសារផែនការលម្អិតស្តីពីសហគមន៍នយោបាយ-សន្តិសុខឆ្នាំ២០២៥ ក្នុងការនាំមកនូវសហគមន៍អាស៊ានដែលប្រកាន់យកច្បាប់ជាមូលដ្ឋាន ការយកចិត្តទុកដាក់លើប្រជាជន និងការយកប្រជាជនជាស្នូល។ ទាក់ទងនឹងបញ្ហានេះ ថ្នាក់ដឹកនាំបានតាំងចិត្តក្នុងការលើកកម្ពស់ថែមទៀត នូវគោលបំណង និងគោលការណ៍ដែលមានចែងនៅក្នុងធម្មនុញ្ញអាស៊ាន។ ថ្នាក់ដឹកនាំក៏បានរំពឹងទុកដល់ការចូលជាភាគីរបស់អៀរ៉ង់ក្នុងសន្ធិសញ្ញាមិត្តភាពនិងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ ព្រមទាំងការសម្រេចចិត្តរបស់រដ្ឋមន្ត្រីការបរទេសអាស៊ានចំពោះសំណើថ្មីៗរបស់ប្រទេស ជាច្រើនក្នុងការចូលជាភាគីក្នុងសន្ធិសញ្ញានេះ។

ចំពោះឧក្រិដ្ឋកម្មឆ្លងដែន និងការរត់ពន្ធគ្រឿងញៀន ថ្នាក់ដឹកនាំបានថ្លែងសរសើរដល់ការងាររបស់អង្គាធរពាក់ព័ន្ធក្នុងការដោះស្រាយការគំរាមកំហែងដែលបង្កឡើងដោយឧក្រិដ្ឋជន លទ្ធិជ្រុលនិយម និងអំពើហិង្សាជ្រុលនិយមនៅក្នុងតំបន់។ ថ្នាក់ដឹកនាំបានរំពឹងទុកដល់ការផ្តល់សច្ចាប័នរបស់ប្រទេសសមាជិកអាស៊ានទាំងអស់លើអនុសញ្ញារបស់អាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។ ថ្នាក់ដឹកនាំបានអំពាវនាវឲ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពចំពោះអនុសញ្ញានេះ ដើម្បីទប់ស្កាត់ការរត់ពន្ធមនុស្ស និងការជួញដូរមនុស្សនៅក្នុងតំបន់។

ថ្នាក់ដឹកនាំបានកត់សម្គាល់អំពីលទ្ធផលដ៏ជោគជ័យនៃកិច្ចប្រជុំលើកទី២ របស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃមជ្ឈមណ្ឌលសកម្មភាពមីនតំបន់អាស៊ាន នៅខែវិច្ឆិកា ឆ្នាំ២០១៦ ដែលក្នុងនោះបានគាំទ្រសំណើរបស់កម្ពុជាសម្រាប់តួនាទីនាយកប្រតិបត្តិបណ្តោះអាសន្នរបស់មជ្ឈមណ្ឌល និងបានអនុម័តគោលការណ៍ណែនាំសម្រាប់ការជ្រើសរើសនាយកប្រតិបត្តិមជ្ឈមណ្ឌលសកម្មភាពមីនតំបន់អាស៊ាន។

អំពីសមុទ្រចិនខាងត្បូង ថ្នាក់ដឹកនាំបានអះអាងឡើងវិញពីសារសំខាន់ក្នុងការថែរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងសេរីភាពនាវាចរ និងការហោះហើរក្នុង និងពីលើសមុទ្រចិនខាងត្បូង។ ថ្នាក់ដឹកនាំបានស្វាគមន៍ ការដាក់ឲ្យដំណើរការគោលការណ៍ណែនាំទាំងឡាយស្តីពីទំនាក់ទំនងខ្សែទូរស័ព្ទពិសេសក្នុងចំណោមមន្ត្រីជាន់ខ្ពស់ក្រសួងការបរទេសនៃប្រទេសសមាជិកអាស៊ាននិងចិន ក្នុងការឆ្លើយតបភាពបន្ទាន់ក្នុងលំហសមុទ្រក្នុងការអនុវត្តសេចក្តីថ្លែងការណ៍ស្តីពីការប្រតិបត្តិរបស់ភាគីនៅសមុទ្រចិនខាងត្បូង និងទន្ទឹងរង់ចាំការដាក់ឲ្យដំណើរការនាពេលឆាប់ៗនូវវិធានការណ៍ឆាប់ប្រមូលផល នោះគឺសេចក្តីប្រកាសរួមស្តីពីការអនុវត្តក្រមសម្រាប់ការពើបប្រទះដោយមិនបានគ្រោងទុកនៅលំហសមុទ្រ (CUES) នៅសមុទ្រចិនខាងត្បូង។

ថ្នាក់ដឹកនាំបានអះអាងជាថ្មីម្តងទៀតពីសារសំខាន់នៃភាពចាំបាច់ក្នុងការពង្រឹងការជឿជាក់ និងទំនុកចិត្តគ្នាទៅវិញទៅមក ការអនុវត្តការអត់ធ្មត់នៅក្នុងការធ្វើសកម្មភាពនានា និងជៀសវាងសកម្មភាព

ដែលអាចធ្វើឲ្យ សភាពការណ៍ស្មុគ្រស្មាញថែមទៀត ហើយបន្តរកដំណោះស្រាយជម្លោះដោយសន្តិវិធី ដោយមិនជ្រើសរើសយកការគំរាមកំហែង ឬប្រើកម្លាំង។

ថ្នាក់ដឹកនាំបានស្វាគមន៍ចំពោះវឌ្ឍនភាពក្នុងការបញ្ចប់ការងារស្តីពីក្របខ័ណ្ឌនៃក្រមប្រតិបត្តិនៃភាគីនៅសមុទ្រចិនខាងត្បូងនៅពាក់កណ្តាលឆ្នាំ២០១៧ ដើម្បីសម្របសម្រួលការបញ្ចប់ឲ្យបានឆាប់ ក្រមប្រតិបត្តិប្រកបដោយប្រសិទ្ធភាព។

ចំពោះបញ្ហានៅឧបទ្វីបកូរ៉េ ថ្នាក់ដឹកនាំបានបង្ហាញនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការវិវឌ្ឍនាពេលថ្មីៗនេះនៅឧបទ្វីបកូរ៉េ រួមមាន ការសាកល្បងនុយក្លេអ៊ែរចំនួន២លើករបស់សាធារណរដ្ឋប្រជាមានិតប្រជាធិតតេយ្យកូរ៉េ នៅឆ្នាំ២០១៦ និងការបាញ់កាំជ្រួចចំងាយឆ្ងាយជាបន្តបន្ទាប់។ ទង្វើរបស់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ បានបង្កឲ្យមានភាពតានតឹងកើនឡើង ដែលអាចប៉ះពាល់ដល់សន្តិភាព និងស្ថិរភាពនៅក្នុងតំបន់ទាំងមូល។

ថ្នាក់ដឹកនាំបានជំរុញសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ឲ្យអនុវត្តយ៉ាងពេញលេញ និងជាបន្ទាន់នូវកាតព្វកិច្ចរបស់ខ្លួន ដែលកើតចេញពីសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងសង្កត់ធ្ងន់ពីសារសំខាន់នៃភាពអត់ធ្មត់ ដើម្បីជាគុណប្រយោជន៍ ក្នុងការថែរក្សាសន្តិភាព សន្តិសុខ និងស្ថិរភាពនៅក្នុងតំបន់ និងនៅលើពិភពលោក។

ភ្នំពេញ, ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៧